# សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត

# The Electoral Reform Alliance (ERA)

ភ្នំពេញថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៤

## លិខិតចំហជូនចំពោះគណៈកម្មការចម្រុះកំណែទម្រង់ការបោះឆ្នោតនៃគណបក្សនយោបាយទាំងពីរ

សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោតសូមអបអរ និងស្វាគមន៍នូវលទ្ធផលដែលគណៈកម្មការចម្រុះកំណែទម្រង់ការបោះឆ្នោតបានដំណើរការ និងបានបញ្ចប់កិច្ចប្រជុំរបស់ខ្លួនទៅលើសេចក្តីសម្រេចរួមចុះនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៤ ដែលបានឯកភាពគ្នាទៅលើការធ្វើកំណែទម្រង់លើចំណុចមួយចំនួន។

ទោះបីជាយ៉ាងណាក៏ដោយ ការជួបប្រជុំរបស់គណៈកម្មការចម្រុះនេះមិនទាន់បានបង្ហាញឱ្យបានច្បាស់លាស់នូវចំណុចជាក់លាក់ដែលបានសម្រេចនោះ ព្រមទាំងខ្វះនូវការប្តេជ្ញាចិត្តពិតប្រាកដក្នុងការធ្វើឱ្យការជួបប្រជុំដំណើរការនេះដោយសកម្ម។

គណៈកម្មការចម្រុះនេះ ត្រូវតែធ្វើការប្រជុំឱ្យបានញឹកញាប់ជាងនេះ ដើម្បីបង្ហាញឱ្យឃើញពីការប្តេជ្ញាចិត្តក្នុងការដោះស្រាយបញ្ហាយ៉ាងពិតប្រាកដ។

សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត សូមអំពាវនាវឱ្យគណៈកម្មការចម្រុះនេះពិនិត្យមើលឡើងវិញនូវរាល់អនុសាសន៍របស់សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត និងសហភាពអឺរ៉ុប ក៏ដូចជាអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សសំរាប់ជាមូលដ្ឋានក្នុងការធ្វើកំណែទម្រង់នេះ។

សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត រីករាយជានិច្ចក្នុងការផ្តល់ឯកសារ និងធ្វើបទបង្ហាញលំអិតជូនគណៈកម្មការចម្រុះនេះ មុនថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤ខាងមុខនេះ។

សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោតសង្ឃឹមយ៉ាងមុតមាំថា នៅកិច្ចប្រជុំលើកក្រោយនៃគណៈកម្មការចម្រុះនេះ ដែលនឹងប្រព្រឹត្តទៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤ នឹងសម្រេចបានជាផែនការសកម្មភាពលម្អិត និងមានពេលវេលាជាក់លាក់។

សម្រាប់ព័ត៌មានបន្ថែមៈ

| ឈ្មោះ | អង្គការ | លេខទូរស័ព្ទ |
|---|---|---|
| • លោក នី ចរិយា | អាដហុក | ០១១ ២៧៤ ៩៥៩ |
| • អ្នកស្រី ពង់ ឈៀវកិច | លីការដូរ | ០១២ ៨០២ ៥០៦ |
| • លោក ព្រាប កុល | តម្លាភាពកម្ពុជា | ០១២ ៨៧៧ ៨៣៣ |
| • លោក ហង្ស ពុទ្ធា | និចហ្វិច | ០១២ ៩៥៩ ៦៦៦ |
| • លោក យង់ គិមអេង | ភីដីភី សិនធ័រ | ០១៦ ៨២៨ ២១១ |
| • លោក គល់ បញ្ញា | ខុមហ្វ្រែល | ០១២ ៩៤២ ០១៧ |
| • លោក សុខ ពិទូរ | វាយ ស៊ី ស៊ី | ០១៧ ២៧៣ ៣០៣ |
| • លោក មក់ ចំរើន | ខេ វាយ អេ | ០១៧ ៧៨៨ ៩៥៥ |
| • លោក គាន ពន្លក | ជ្រាក | ០១២ ៥៥១ ៤៦៦ |
| • លោក ហុង គឹមសួន | សម្ព័ន្ធស៊ីសា | ០១២ ៩៤៥ ៥០៥ |
| • លោក ប៉ា ងួនទៀង | ស៊ី ស៊ី អាយ អឹម | ០៦០ ៤០៩៩ ៩៩ |